**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ពុធ ៨ កើត ខែ មិគសិរ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីប្រគល់វិញ្ញាបនបត្រកម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា" វគ្គទី២ រដូវកាលទី២

**នារសៀលថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២៣ វេលាម៉ោង ២:០០ រសៀល ដល់ម៉ោង ៤:០០ រសៀល** នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) បានសហការជាមួយមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ", ក្រុមហ៊ុន META និងគាំទ្រដោយ ក្រុមហ៊ុន Aleph បានរៀបចំ **ពិធីប្រគល់វិញ្ញាបនបត្រនៃកម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា" រដូវកាលទី២**។ ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត តាំង ងួនលី** នាយកនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល, **លោកបណ្ឌិត ហេង ភក្តី** អ្នកគ្រប់គ្រងគោលនយោបាយសាធារណៈនៃក្រុមហ៊ុន META និង **លោក ហែម សុបញ្ញា** នាយកគ្រប់គ្រងក្រុមហ៊ុន Aleph នៅកម្ពុជា អមជាមួយការចូលរួមពីសំណាក់គ្រូបណ្តុះបណ្តាល សិក្ខាកាម និងភ្ញៀវកិត្តិយសជាច្រើនទៀត។

**កម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា"** មានរយៈពេល៨សប្តាហ៍ ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ជាពិសេសការធ្វើទីផ្សារលើប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងចំណោមសហគ្រាស និងអាជីវកម្មនានានៅកម្ពុជា។ កម្មវិធីបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងចំនួន ២លើក ក្នុងឆ្នាំ២០២៣ ដែលមានចំនួនសិក្ខាកាមចូលរួមសរុបគឺ **១០០នាក់**។

ជាលទ្ធផល កម្មវិធីបណ្តុះបណ្តាលនេះ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលគាប់ប្រសើរដូចការរំពឹងទុកថែមទាំងទទួលបានធាតុចូលល្អៗជាច្រើន តាមរយៈការចែករំលែកទស្សនទាន, គំនិត នវានុវត្តន៍ និងបទពិសោធន៍ជាក់ស្តែង ពីសំណាក់វាគ្មិនកិត្តិយស និងអ្នកចូលរួមទាំងអស់។